# សន្លឹកឆ្នោតរបស់អ្នក សម្លេងរបស់អ្នក

## ការបោះឆ្នោតដកចេញអភិបាលរដ្ឋកាលីហ្វញ៉ា ថ្ងៃទី14 ខែកញ្ញា ឆ្នាំ2021

## តើមានអ្វីនៅក្នុងសន្លឹកឆ្នោត?

**ការបោះឆ្នោតដកចេញអភិបាលរដ្ឋកាលីហ្វញ៉ាគឺធ្វើនៅថ្ងៃអង្គារ ទី14 ខែកញ្ញា។**

មានសំណួរចំនួនពីរនៅក្នុងសន្លឹកឆ្នោតដែលពលរដ្ឋកាលីហ្វញ៉ាមានសិទ្ធិគ្រប់រូបអាចបោះឆ្នោតទៅលើ៖

1. តើអ្នកចង់ដកលោកអភិបាលចេញឬទេ(ដកគាត់ចេញពីតំណែង)?
2. ប្រសិនបានដកលោកអភិបាលចេញ តើអ្នកចង់ឱ្យនរណាជំនួសគាត់វិញ?

ប្រសិនមានអ្នកបោះឆ្នោតច្រើនជាង50% និយាយថា«អត់ទេ»ចំពោះសំណួរទីមួយ លោកអភិបាលនៅកាន់តំណែងដដែល។

ប្រសិនមានអ្នកបោះឆ្នោតច្រើនជាង៥០% និយាយថា«បាទ/ចាស»

បេក្ខជនដែលទទួលបានការបោះឆ្នោតច្រើនជាងគេលើសំណួរទីពីរនឹងក្លាយជាអភិបាល។

## តើខ្ញុំបោះឆ្នោតនៅក្នុងការបោះឆ្នោតដកចេញនេះដោយរបៀបណា?

**គ្រប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងរដ្ឋកាលីហ្វញ៉ានឹងទទួលសន្លឹកឆ្នោតមួយតាមសំបុត្រ** ប្រហែលមួយខែមុនដល់ថ្ងៃអង្គារ ទី14 ខែកញ្ញា។ សូមចុះឈ្មោះបោះឆ្នោតតាមរយៈ registertovote.ca.gov។ តើអ្នកមិនបានដឹងថាអ្នកបានចុះឈ្មោះបោះឆ្នោតហើយឬនៅទេ? សូមចូលតាម voterstatus.sos.ca.gov ដើម្បីពិនិត្យមើលពីស្ថានភាពនៃការចុះឈ្មោះរបស់អ្នកឬដើម្បីចុះឈ្មោះបោះឆ្នោត។

**ការផុតកំណត់ចុះឈ្មោះសម្រាប់ការបោះឆ្នោតដកចេញ គឺនៅថ្ងៃច័ន្ទ ទី30 ខែសីហា ឆ្នាំ2021។**

## មានបីរបៀបដើម្បីបោះឆ្នោត៖

### 1. បោះឆ្នោតតាមសំបុត្រ




អ្នកអាចបំពេញហើយផ្ញើត្រឡប់មកវិញនៅពេលអ្នកទទួលបានសំបុត្រនោះ។ **គ្មានតែមប៉ុស្តិ៍? គ្មានបញ្ហាទេ។ ផ្ញើសន្លឹកឆ្នោតរបស់អ្នកមកវិញឱ្យបានឆាប់** ពីព្រោះសន្លឹកឆ្នោតនឹងត្រូវបានវាយត្រាពីលើនៅថ្ងៃបោះឆ្នោត ថ្ងៃអង្គារ ទី14 ខែកញ្ញា។

### 2. ទម្លាក់សន្លឹកឆ្នោតរបស់អ្នក




អ្នកអាចទម្លាក់សន្លឹកឆ្នោតរបស់អ្នកនៅ**ទីតាំងបោះឆ្នោតណាមួយក៏បាន**នៅក្នុងស្រុករបស់អ្នក។ ស្រុកមួយចំនួនក៏នឹងផ្តល់នូវ**ទីតាំងទម្លាក់សន្លឹកឆ្នោតមានសុវត្ថិភាព**ផងដែរ។ សម្រាប់ការពិនិត្យមើលព័ត៌មានលម្អិតនិងទីតាំង សូមចូលពិនិត្យមើលតាមរយៈ caearlyvoting.sos.ca.gov។ ប្រសិនអ្នកសម្រេចចិត្តទម្លាក់សន្លឹកឆ្នោតរបស់អ្នក អ្នកត្រូវទម្លាក់សន្លឹកឆ្នោតមិនឱ្យយឺតជាង **ម៉ោង8យប់ នាថ្ងៃបោះឆ្នោត ទី14 ខែកញ្ញា**ជាដាច់ខាត។

LWV LEAGUE OF WOMEN VOTERS® OF CALIFORNIA EDUCATION FUND

ASIAN AMERICANS ADVANCING JUSTICE ASIAN LAW CAUCUS

### 3. បោះឆ្នោតដោយផ្ទាល់

ទីតាំងបោះឆ្នោតរបស់អ្នកអាចមានភាពខុសប្លែកគ្នាឆ្នាំនេះ។

នៅក្នុងស្រុកមួយចំនួនអ្នកអាចបោះឆ្នោតនៅទីតាំងបោះឆ្នោតមួយណាក៏បាន។

នៅក្នុងស្រុកផ្សេងៗទៀតអ្នកត្រូវតែទៅកាន់ទីតាំងបោះឆ្នោតដែលបានកំណត់ជាពិសេស។



**ការបោះឆ្នោតជាមុន**ដែលចាប់ផ្តើមមុនថ្ងៃបោះឆ្នោតនឹងអាចរកបាននៅក្នុងទីតាំងមួយចំនួន។

នៅទីតាំងបោះឆ្នោតដោយផ្ទាល់ អ្នកអាច៖

- បោះឆ្នោតដោយផ្ទាល់។
- ទម្លាក់សន្លឹកឆ្នោតដែលបានបំពេញរបស់អ្នក។
- បោះឆ្នោតជាមួយនឹងម៉ាស៊ីនបោះឆ្នោតដែលអាចទៅរកប្រើប្រាស់បាន។
- សុំរកជំនួយនិងសម្ភារៈបោះឆ្នោតដែលមានភាសាចម្រុះ។
- ស្វែងរកទីតាំងបោះឆ្នោតរបស់អ្នកតាមរយៈ findmypollingplace.sos.ca.gov។

## សម្រាប់ព័ត៌មានពីការបោះឆ្នោតបន្ថែមទៀត សូមចូលពិនិត្យមើលក្នុងគេហទំព័រទាំងនេះ៖

| | |
|---|---|
| registertovote.ca.gov | ចុះឈ្មោះបោះឆ្នោត |
| findmypollingplace.sos.ca.gov | ស្វែងរកទីតាំងបោះឆ្នោតរបស់អ្នក |
| votersedge.org | ស្វែងរកពីការពិតនានាមុនអ្នកបោះឆ្នោតជាមួយនឹង Voter’s Edge, សម្ព័ន្ធអ្នកបោះឆ្នោតជាស្ត្រីរបស់មូលនិធិអប់រំរដ្ឋកាលីហ្វញ៉ា( the League of Women Voters of California Education Fund) និងឧបករណ៍ពិនិត្យសន្លឹកឆ្នោតតាមអនឡាញរបស់ MapLight |